សម្លេងខ្មែរនៅបរទេស

# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីពុទ្ធភាសិតមួយបទពោលថា សច្ចំ វេ អមតា វាចា ប្រែថា ពាក្យពិតមែនជាពាក្យពុំស្លាប់

web site: hoksavann.org

ថ្ងៃទី២៦ មិថុនា ២០០៥

ពាក្យថា សច្ចំ វេ អមតា វាចា ប្រែថា ពាក្យពិតមែនជាពាក្យពុំស្លាប់នេះ បានសេចក្តីថា ពាក្យពិតមែនជាពាក្យត្រូវរហូត ដូចជាពុទ្ធភាសិតជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ព្រះអង្គត្រាស់សំដែងជាង២៥០០ឆ្នាំកន្លងមកហើយ ពាក្យនៅតែពិតដដែល ហើយនឹងនៅតែពិតជានិច្ច ព្រោះជាសច្ចៈ សកល ពុំមែនជាសច្ចៈសំរាប់តែទីកន្លែងមួយៗទេ គឺជាការពិតទូទៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា ដូចជាពាក្យថា ធ្វើបាបបានបាប ធ្វើបុណ្យបានបុណ្យ, សង្ខារទាំងឡាយមានខន្ធប្រាំជាដើម ប្រព្រឹត្តទៅជាអនិច្ចំ ពុំទៀង ជាទុក្ខ និងជាអនត្តា ពុំមែនជារបស់ខ្លួន គឺត្រូវគ្រប់សង្ខារទាំងអស់ គ្រប់ជនជាតិទាំងអស់ក្នុងលោក ទោះបីអ្នកមិនកាន់ព្រះពុទ្ធសាសនាក៏ដោយ ។ នេះជាពាក្យពិតមិនចេះស្លាប់ គឺជាពាក្យពុំប្រែប្រួលទៅតាមពេលវេលានិងទីកន្លែងឡើយ ព្រោះមានពាក្យខ្លះ ដូចជាសុភាសិតបូរាណ ឬសុភាសិតរបស់ជនជាតិដទៃ ដែលកើតពីមនុស្សធម្មតាពោលឡើង ត្រូវបានតែតាមវប្បធម៌របស់ខ្លួន និងតាមពេលវេលាប៉ុណ្ណោះ ពុំមែនជាសច្ចៈសកលឡើយ សច្ចៈបែបនេះ គេហៅថា លោកិយសច្ចៈ ឬសម្មតិសច្ចៈ ជាសច្ចៈធម្មតារបស់មនុស្សដែលបញ្ចេញទស្សនៈតាមការយល់ឃើញរបស់ខ្លួន ។ ចំណែកសច្ចៈ ដែលព្រះពុទ្ធត្រាស់ដឹង ដែលហៅថាអរិយសច្ចៈ ឬបរមត្ថសច្ចៈ ជាសច្ចៈដ៏ប្រសើរខ្ពង់ខ្ពស់ស្របតាមច្បាប់ធម្មជាតិ ។ ពាក្យថាធម្មជាតិ គឺពិតតាមកំណើតដើម ឬធាតុរបស់វាប្រព្រឹត្តទៅយ៉ាងណា វានៅតែប្រព្រឹត្តទៅយ៉ាងនោះ គេពុំអាចកែច្បាប់ធម្មជាតិនោះបានឡើយ ដូចជារដូវប្រចាំឆ្នាំនីមួយៗ បើដល់ពេលរដូវត្រជាក់ហើយ តែងតែត្រជាក់ពុំអាចប្រែជាក្តៅក្នុងរដូវត្រជាក់នោះឡើយ នេះជាច្បាប់ធម្មជាតិ ពុំមែនព្រះជាម្ចាស់

អង្គណាបង្កើតឲ្យមានឡើយ ។ ទ្រឹស្តីកម្មផលជាច្បាប់ធម្មជាតិ គឺអំពើបែបណាតែងចេញផលបែបនោះ គ្រាន់តែផ្តល់ផលយូរឬឆាប់តាមហេតុការណ៍ដែលវាអាចឲ្យផលបាន គឺពិតជាបញ្ចេញផលតាមហេតុឬអំពើរបស់វា ដោយគ្មានអំពើណាមួយពុំមានបញ្ចេញផលនោះឡើយ ហើយផលដែលកើតឡើងដោយសារមានហេតុនេះជាទ្រឹស្តីមានទំនាក់ទំនងរវាងហេតុនិងផល មានប្រព័ន្ធទាក់ទងគ្នាតាមលក្ខណៈស្របតាមវិទ្យាសាស្ត្រ គេពុំអាចកែប្រែទ្រឹស្តីដែលមានសច្ចភាពនេះបានឡើយ ។ ពាក្យពិតជាពាក្យពុំស្លាប់ គឺជាពាក្យនៅតែពិតជានិច្ច ហើយជាពាក្យមានតម្លៃគ្រប់ពេលវេលានិងគ្រប់ទីកន្លែង ។ ផ្ទុយទៅវិញ បើពាក្យពុំពិតនឹងរស់នៅពុំបានយូរឡើយ នឹងត្រូវវិនាសសាបសូន្យទៅវិញ នៅពេលការពិតត្រូវលេចចេញមក ។ កាលណាគេដឹងការពិត ពាក្យនោះត្រូវអស់តម្លៃខ្លួនឯង ដូចពាក្យចាស់បូរាណខ្មែរពោលថា ពាក្យភូតចាញ់អាត្មា ។ ពាក្យពុំពិតតាមន័យព្រះពុទ្ធសាសនា សំដៅយកវាចាដែលចាត់ទុកក្នុងទិដ្ឋិការយល់ខុស គឺរបស់ពុំទៀងសំគាល់ថាទៀង, របស់ជាទុក្ខសំគាល់ថាសុខ គឺរបស់ជាអនត្តាសំគាល់ថាអត្តា គឺថាជាខ្លួន របស់មិនស្អាតសំគាល់ថាស្អាត របស់ជាបាបសំគាល់ថាជាបុណ្យ របស់ជាគុណសំគាល់ថាជាទោសរបស់អាក្រក់សំគាល់ថាល្អ របស់វិនាសសំគាល់ថាចំរើនជាដើម ។ កាលណាបើបុគ្គលមានគំនិតយល់ខុសនោះព្រមទាំងណែនាំគេឲ្យយល់ខុស បុគ្គលនោះនឹងយល់នូវសេចក្តីវិនាស ថែមទាំងធ្វើគេឲ្យវិនាសផង ។ ត្រង់នេះហើយដែលព្រះពុទ្ធបានហាម គឺកុំសេពគប់ជនពាល ដែលមានគំនិតយល់ខុសប្រាសចាកសភាពពិតនៃព្រះធម៌ ដែលនាំឲ្យសិក្សាតាមគំនិតយល់ខុសនោះ ។

ចំពោះអ្នកដឹកនាំគ្រប់ប្រភេទ បើដឹកនាំក្នុងផ្លូវខុសហើយ នឹងនាំឲ្យអ្នកដើរតាមទទួលនូវសេចក្តីវិនាស ដូចអ្នកកាច់ចង្កូតរថយន្ត កប៉ាល់ ឬនាវា បើអ្នកបើកពុំស្ទាត់ជំនាញ ពុំដឹងផ្លូវច្បាស់ ឬពុំប្រុងប្រយ័ត្នទេ យានជំនិះទាំងនោះនឹងត្រូវលិចឬក្រឡាប់ ធ្វើឲ្យអ្នកជិះស្លាប់ឬត្រូវរបួស ។ យ៉ាងណាមិញ អ្នកកាច់ចង្កូតស្រុកទេសក៏ដូចគ្នា បើអ្នកដឹកនាំមានគំនិតយល់ខុស មានផែនការមិនល្អ មិនអាចធ្វើឲ្យស្រុកទេសចំរើនលូតលាស់ឡើយ តែនឹងធ្វើឲ្យប្រទេសវិនាសទៅវិញ ។ មេដឹកនាំព្រះពុទ្ធសាសនា គឺព្រះពុទ្ធព្រះបរមគ្រូ ព្រះអង្គត្រាស់ដឹងនូវធម៌ពិត ជាធម៌ដឹកនាំមនុស្សសត្វឲ្យចេញចាកទុក្ខ ដែលសព្វថ្ងៃនេះមនុស្សកាន់តែមានចំនួនច្រើនឡើងក្នុងពិភពលោកទទួលយកធម៌ព្រះអង្គទៅប្រតិបត្តិតាម ៕